មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0157**

# សម្ភាសន៍ជាមួយឈ្មោះ ពត គីមលាង ភេទស្រី អាយុ៥៨ឆ្នាំ
# មុខងាររជំនាន់ខ្មែរក្រហម “ធ្វើការនៅក្នុងកងចល័ត”
# រស់នៅភូមិស្រះកើត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
# ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១
# សម្ភាសន៍ដោយៈ ឆាយ ឈុនលី
០០:៤០:៥៤
**១៩ទំព័រ**

ឈុនលី : មីង ជាដំបូងខ្ញុំសុំណែនាំខ្លួនសិន!ខ្ញុំឈ្មោះឈុនលី ហើយដូចលោកពូប្រធានភូមិបាន ជំរាបនអីចឹងថាខ្ញុំចង់ដឹងប្រវត្តិដែលមីងធ្វើការនៅត្រពាំងថ្មហត់នឿយយ៉ាងម៉េចៗអីចឹងទេ ទៅណាស ។

គីមលាង : ហត់នឿយហ្នឹងឯង!មួយថ្ងៃគេឲ្យលើក២ម៉ែត្រគីប ស្អែកឡើងគេឲ្យថែម៣ម៉ែត្រគីប ។

ឈុនលី : សំរាប់ម្នាក់ឯងហ្អី?

គីមលាង : ម្នាក់ ស្អែក...

ឈុនលី : ចឹងមីងខ្ញុំសុំយកទៅសរសេរសៀវភៅអីចឹងណាស ហើយខ្ញុំសុំថតរូបអីបានទេ?

គីមលាង : ថតទៅ!

ឈុនលី : ហើយខ្ញុំសុំថតសំលេងមីងដែរព្រោះខ្ញុំកត់អត់ទាន់ចឹង?

គីមលាង : ចេះតែឆ្លើយឲ្យបាន!

ឈុនលី : ចាំ

គីមលាង : ដែរ...លើកមុនដំបូង២ម៉ែត្រគីបដល់ស្អែកឡើងគេបន្ថែម៣ម៉ែត្រគីប ៣ម៉ែត្រគីបទៅដល់ ៥ម៉ែត្រគីបក៏លើកមិនរួច គេមិនឲ្យឡើងមកហូបបាយ ។ គេមិនឲ្យឡើងមកហូបបាយក៏ ដេកនៅកន្លែងលើកម៉ែត្រគីបនោះ បើលើកមិនរួចគេមិនឲ្យឡើងទេកនូ!

ឈុនលី : ចុះមីងបើតាមខ្ញុំសួរមីងៗនៅកន្លែងផ្សេងទៀតណាស ក្រែងលគាត់ច្រលំកន្លែងទេដឹង គាត់ថាគេចែក២ម៉ែត្រគីបកន្លះ ហើយ២ម៉ែត្រគីបកន្លះហ្នឹងសំរាប់មួយក្រុមដប់នាក់?

គីមលាង : អត់មានទេ!ម្នាក់ណាស២ម៉ែត្រគីប ។ សួរឈ្មោះ ឃីម ហ្អី?

ឈុនលី : មីង លឿត ស៊ីលឿត! ទៅជាមួយទេមីង?

គីមលាង : អត់ស្គាល់ទេ ។

ឈុនលី ៖ នៅភូមិកណ្ដាល!

គឹមលាង ៖ នៅនេះហ្អី?

ឈុនលី ៖ ចា៎

គឹមលាង ៖ បើខ្ញុំទៅមុនដឹបូងគេឲ្យលើក២ម៉ែត្រគីប ។

ឈុនលី ៖ តែម្នាក់ៗឯងចឹងម៉ងហ្អី?

គឹមលាង ៖ ចា៎

ឈុនលី ៖ ជំរៅប៉ុន្មានទៅ?

គឹមលាង ៖ ជំរៅកន្លះម៉ែត្រ បណ្ដោយ២ម៉ែត្រ ។

ឈុនលី ៖ ចុះទទឹង?

គឹមលាង ៖ ២ម៉ែត្រគីប ដល់ស្អែកឡើង៣ម៉ែត្រគីប ដល់ខានស្អែកឡើងគេតំឡើង៤ម៉ែត្រ ៥ម៉ែត្រ ទៅលើកអត់រួច ។ ខ្ញុំលើកអត់រួច ដល់លើកអត់រួចគេមិនឲ្យឡើងទៅកន្លែងទេ ។

ឈុនលី ៖ ចឹងយើងលើកដល់យប់ទៀត?

គឹមលាង ៖ យប់ក៏លើក លើករួចហើយក៏មិនហ៊ានឡើងមកហូបបាយ គេហៅឡើងមកហូបបាយខ្លាច លើកមិនរួចឲ្យគេ ដល់ហើយខំលើកឲ្យរួចនឹងអាលមកដេក ហើយទឹកក៏មិនមានផឹកទៀត ទឹកចែកគ្នាពីរបីស្លាបព្រា កន្លែងនោះអត់ទឹកណាស់ ផឹកតែអណ្ដូង បើអ្នកណាទៅដងទាន់ ទាន់ បើទៅមិនទាន់អត់មានទឹកហូបទេ ហើយឡានមានតែគេដឹកទឹកមកឲ្យដាំបាយ ដាំបាយមកហូបមានតែទឹកប្រហុកហើយនឹងត្រួយលំពុក ឈ្នាលមាន់ ។

ឈុនលី ៖ ត្រួយអីគេមីង?

គឹមលាង ៖ ត្រួយឈ្នាលមាន់ លំពុក!

ឈុនលី ៖ លំពុកម៉េចទៅមីង?

គឹមលាង ៖ ដើមលំពុកនៅក្នុងព្រៃចេះតែហូបឲ្យតែរស់ទៅណាស ។

ឈុនលី ៖ លំពុក?

គឹមលាង ៖ ហ្នឹងឯង ហើយគេមានថ្នាំព្យាបាលដែរតែគេឲ្យតែថ្នាំអាចន៍ទន្សាយ ថ្នាំខ្មែរយើង ហើយសម័យនោះកំសត់ករណាស់កូនអើយ!ហើយចេញថៃពីខ្លួនមិនមានទឹកមុជទេ មានតែ ទឹកគេឲ្យយើងផឹកតិចតួចៗ អត់មានទឹកមានតែទឹកដាំបាយ ទឹកមុជអត់មានទេ ចេញចៃពី ខ្លួន តាមអាវទ្រនាប់ ។

ឈុនលី ៖ នៅរយៈពេលប៉ុន្មានទៅបានដល់ថ្នាក់ចេញចៃ?

គីមលាង ៖ រយៈពេលពីរបីថ្ងៃ ដល់មកនៅគរបីដើមបានមានទឹកមុជ ។

ឈុនលី ៖ ចឹងនៅត្រពាំងថ្ម មីងទៅហ្នឹងឆ្នាំណា?

គីមលាង ៖ ទៅនែ!ប្រាប់ឆ្នាំក៏មិនកើត កាលនោះខ្ញុំចល័តនៅឯគរបីដើម អស!នៅឯពរគូអីណោះ គេឲ្យខ្ញុំទៅច្រូតស្រូវ ដល់ច្រូតស្រូវរួចគេស្មាក់ឡើងឲ្យទៅវែកដីហើយខ្ញុំទៅយកបង្គីរនៅផ្ទះតាក្រក ។

ឈុនលី ៖ តាក្រកហ្នឹងមេហ្អី?

គីមលាង ៖ តាក្រកហ្នឹងមេខ្មែរ...

ឈុនលី ៖ មេកងចល័តហ្អី?

គីមលាង ៖ ខ្មែរក្រហមណាសកាលសម័យបីឆ្នាំ ហើយដល់លើករួចទៅមិនមានអីទេកូនអើយដើរយប់ព្រលប់មក ខ្លាចពស់ខ្លាចអី ខ្លាចគេផង ដល់នេះទៅលើកនៅសង្កាត់ស្រះជីកទៀត ដល់មកស្រះជីកនៅកន្លែងនោះមានទឹកផឹកខ្លះ ហើយដល់យប់ឡើងគេឲ្យលើកម៉ែត្រគីប ៣ម៉ែត្រគីបទៀត ហើយលើកមិនរួច ។ បាយមានហូបដែរតែអត់ទឹកផឹក ។ បាយក៏លេបមិនរួចដែរបើអត់ទឹកផឹកហើយលេបបាយមិនរួចទេកូន ហើយទឹកក៏អត់ផ្លូតអត់ទឹកផឹកហើយ ។ បើអ្នកណាដែលទៅយកទឹកបានម្នាក់បីស្លាបព្រាស្មើគ្នា ។

ឈុនលី ៖ ម្នាក់បីស្លាបព្រា?

គីមលាង ៖ ហ្នឹងហើយ ហើយអណ្តូងនោះជីក បើអ្នកណាដងបានក៏បានអ្នកណាដងមិនបានដណ្តើមគ្នា ។ កូនកាំម៉ែលប៉ុននេះដាក់ទំលាក់ទៅក្នុងអន្លង់ ហើយដណ្តើមគ្នាមក ហើយដល់បានម៉ាបំពង់ឬស្សីក៏មកចែកគ្នាបានម្នាក់៣ស្លាបព្រាយកមកឲ្យផឹក ។

ឈុនលី ៖ ៣ស្លាបព្រាមិនបានសើមមាត់ផងហ្នឹង?

គីមលាង ៖ បានសើមមាត់អីកូន ដល់បានហើយទៅទៀត ទៅវែកឲ្យគេទៀត ទៅនៅចាំដល់យប់ទាល់តែមានទឹកទៅក៏វែកមកឲ្យគេផឹក ។ បើមិនបានទឹកឲ្យគេផឹកទេ គេដាក់ម៉ែត្រគីបឲ្យឯងវែកទៀត ។

ឈុនលី ៖ ឲ្យយើងវែកដីហើយទៅវែកទឹកទៀត?

គីមលាង ៖ ទេ!វែកដីគេមិនបានឲ្យយើងទៅវែកទឹកទេ រួចដាក់ខ្ញុំនេះឲ្យអ្នកវែកទឹកណាស មួយក្រុមដប់នាក់មានម្នាក់ទៅវែកទឹក ទៅរកទឹកឲ្យគេផឹក ហើយយើងរកទឹកមិនបានឲ្យគេផឹកគេចាប់ដាក់ម៉ែត្រគីប ។ គេធ្វើបាបយើងណាស់ សម័យនោះកំសត់ណាស់កូនអើយ ហូបតែផ្លែឈើតាមព្រៃ ។

ឈុនលី ៖ ផ្លែអីខ្វះទៅមីង?

គឹមលាង ៖ ផ្លែលំពុកនេះឯងដែលថាមិញហ្នឹង ផ្លែលំពុក ត្រូយលំពុកហូបតែហ្នឹងទឹកប្រហុកដល់បាន ផ្លែនោះមកក៏ស្ងោរ ។

ឈុនលី ៖ លំពុកហ្នឹងផ្លែម៉េចទៅមីង?

គឹមលាង ៖ ផ្លែប៉ុនៗមេដៃដូចផ្លែខ្ទឹម ស្ងោរមកក៏ដូចចេកយកមក កំសត់ណាស់ ។

ឈុនលី ៖ ចឹងមួយក្រុមដប់នាក់ហ្អីមីង?

គឹមលាង ៖ ម៉ាក្រុមដប់នាក់ ឲ្យទៅរែកទឹកយកមកចែកគ្នាបានបីស្លាបព្រារួច...

ឈុនលី ៖ ទឹកហ្នឹងស្អាតទេ?

គឹមលាង ៖ ទឹកស្អាតណាស់ ទឹកអណ្តូង ។

ឈុនលី ៖ ឆ្ងាយ?

គឹមលាង ៖ ឆ្ងាយណាស បើទៅរកលឿនឲ្យគេដឹកបាន តែគេទំលាក់អាសំរាប់ដងទឹកអណ្តូងនោះបើគេ ដងបានមុនគេបានច្រើន បើយើងមិនបានមុនក៏អត់ អត់ហើយសម័យនោះ ។

ឈុនលី ៖ អណ្តូងហ្នឹងអត់ទឹកដែរ?

គឹមលាង ៖ អត់ អត់ទឹកណាស់ ។

ឈុនលី ៖ ចឹងមីងខ្ញុំសុំសួរបកបន្តិចណាស មីងឈ្មោះពេញឈ្មោះអី?

គឹមលាង ៖ ឈ្មោះពត គឹមលាង ។

ឈុនលី ៖ ពុត?

គឹមលាង ៖ ពត! គឹមលាង ។

ឈុនលី ៖ ពត គឹមលាង ហៅវ៉ាន?

គឹមលាង ៖ ចា៎

ឈុនលី ៖ វ៉ានហ្នឹងឈ្មោះពេលណា?

គឹមលាង ៖ ប្រែកាលបដិវត្តិខ្លាចគេវៃចោល ។

ឈុនលី ៖ ហ្អូស!ឈ្មោះនេះឈ្មោះចិន?ពត គឹមលាង ឈ្មោះចិន?

គឹមលាង ៖ ឈ្មោះដើម!

ឈុនលី ៖ ចា៎ ឈ្មោះរបៀបឈ្មោះចិនបានដូរដាក់ឈ្មោះវ៉ាន ដូរសម័យ៧៥ហ្នឹង?

គឹមលាង ៖ សម័យ៧៥ ។

ឈុនលី ៖ ហើយចុះស្រុកកំណើតមីងនៅឯណា?

គឹមលាង ៖ ស្រុកកំណើតកើតនៅភូមិស្រែះខាងកើត ។

ឈុនលី ៖ អាយុប៉ុន្មានមីង?

គឹមលាង ៖ អាយុ៥៨ឆ្នាំ ។

ឈុនលី ៖ ៥៨ឆ្នាំ និយាយថាស្រុកកំណើតមីងនៅហ្នឹងម៉ងហ្អី?

គឹមលាង ៖ ស្រុកកំណើតកើតនៅស្រែះខាងកើតនេះឯង ។

ឈុនលី ៖ ស្រែះកើត អានេះបច្ចុប្បន្ននៅស្រែះកើតដែរ?

គឹមលាង ៖ ហ្នឹងហើយ កើតកំណើតមកនៅក្នុងភូមិនេះ ។

ឈុនលី ៖ ឃុំព្រះនេត្រព្រះ?

គឹមលាង ៖ ហ្នឹងហើយ ។

ឈុនលី ៖ ហើយឆ្នាំណាដែលខ្មែរក្រហមចូលមកដល់ហ្នឹង?

គឹមលាង ៖ មិនដឹងឆ្នាំអីណាស ចំណាំឆ្នាំមិនបាន ។

ឈុនលី ៖ ៧៥ ៧៤?

គឹមលាង ៖ ៧៥ ។

ឈុនលី ៖ ៧៥ ហ្នឹងអាខ្ទង់...

គឹមលាង ៖ សម័យបីខែប៉ុន្មានក៏មិនដឹង!

ឈុនលី ៖ ៧៥ ខែ៤ហ្អីខែចូលឆ្នាំ?

គឹមលាង ៖ មិនដឹងខែអីទេកូន បើមិនដែលបានចំណាំ ។

ឈុនលី ៖ ចុះពេលខ្មែរក្រហមចូលមកដំបូងមីងនៅឯណា?

គឹមលាង ៖ នៅផ្ទះ នៅភូមិស្រែះនេះឯង ។

ឈុនលី ៖ ចូលមកដល់ស្មើណាមីង?

គឹមលាង ៖ ខ្មែរក្រហមនោះអី?

ឈុនលី ៖ ចា៎

គឹមលាង ៖ ចូលមកយប់ ផ្ទះមីងតូចចូលមកដល់ ខ្មែរក្រហមចូលមកយប់រៀបអង្ករទៀត កាលមិនទាន់បានទៅចល័តម៉េះនោះ ស្រាប់តែបួនប្រាំថ្ងៃទៀតគេដាក់ស្អីរួមទាំងអស់គេថាពុកម៉ែចង់បានឆ្នាំងបាយជុំគ្នាទេ?

ឈុនលី ៖ ចូលមកសួរទៀត?

គឹមលាង ៖ សួរ ។

ឈុនលី ៖ ហើយទៅឆ្លើយថាម៉េច?

គីមលាង ៖ មិនហ៊ានឆ្លើយខ្លាចគេវ៉ៃចោល នៅតែស្ងៀម បើយើងមិនឆ្លើយតាមគេខ្លាចគេវ៉ៃចោល ថាចង់ហ្នឹងហើយ ថាចង់បានរូមនេះឯង ដល់រូមនោះរូមគេយកទៅវ៉ៃចោលអស់នោះណាសកូន ។

ឈុនលី ៖ កាន់កាំភ្លើងកាន់អីមកចឹងទៅ?

គីមលាង ៖ អត់ដែលកាន់ទេ ។

ឈុនលី ៖ ទាហ៊ានខ្មែរក្រហមណាស?

គីមលាង ៖ ហួស!ទាហ៊ានកាន់កាំភ្លើង កាន់កាំភ្លើងមកក៏សុំតែអង្ករសុំតែអីទៅ ។ ហត់តែសុមអង្កររួចក៏ទាហានអីដាំទៅមានអីបាញ់គ្នាអាកាល៧៥ហើយណាស អានេះសម័យ៧៥ដែលយាក់ណាមចូលមកហើយ ។

ឈុនលី ៖ ហ្អាក!អាហ្នឹង៧៩ហ្នឹង?

គីមលាង ៖ ៧៩ហើយហ្អី?

ឈុនលី ៖ ៧៩ ពេលវៀតណាមចូល ។

គីមលាង ៖ យាក់ណាមចូលមកហើយ ខ្មែរក្រហមចូលមកសុំអង្ករ អត់ទាន់ស្រួលបួលណាសកាលនោះ ។

ឈុនលី ៖ អាហ្នឹងវៀតណាមចូលហើយទេហ្អី?

គីមលាង ៖ ចូលហើយដឹង?

ឈុនលី ៖ វៀតណាមចូលហើយអាហ្នឹង៧៩ហើយមីង បើ៧៥ពេលខ្មែរក្រហមចូលមកដំបូង ។

គីមលាង ៖ នោះឯងចូលមកដំបូង ។

ឈុនលី ៖ ចូលមកដំបូងសុំអង្ករដែរ?

គីមលាង ៖ សុំ ។

ឈុនលី ៖ ហើយចូលមកប៉ុន្មានថ្ងៃបានរៀបចំឲ្យមានសហករណ៍?

គីមលាង ៖ តែមួយយប់ប៉ុណ្ណោះឯង?

ឈុនលី ៖ ជម្លៀសប្រជាជនចេញ?

គីមលាង ៖ ជម្លៀសស្រាប់តែ...ដែរខ្ញុំនិយាយចេះ លើកសារថ្មីចេះវិញ...

ឈុនលី ៖ ចាំ៎ មីង!

គីមលាង ៖ ដែលខ្ញុំចល័តមកនេះ ដែរយាក់ណាមចូលតើបានមកនេះកុំអីមិនឃើញមុខម៉ែទេ ។

ឈុនលី ៖ នៅតែកន្លែងនោះដដែល?

គីមលាង ៖ នៅគរបីដើម មកនេះហើយនៅគរបីដើមអីជិតព្រៃមានឯណោះ ។ ព្រៃមានហ្នឹងមានគេលើកផ្ទះក្បឿងឲ្យ វែង ផ្ទះចល័ត ។

ឈុនលី ៖ ព្រៃមាន?

គីមលាង ៖ នោះឯងតែយាក់ណាមចូលមកបានឃើញមុខម៉ែ ។ ដល់មកដល់មិនឃើញគាត់ទេ គាត់ទៅនៅអីវាលស្រែណាទេជិតស្រម៉ោចអីណោះ ផ្ទះក៏គេរើអស់រលីង ។ កំសត់ណាស់កូនអឺយ! ហើយឪក៏គាត់ស្លាប់ទៀតកាលសម័យនោះ ។

ឈុនលី ៖ គាត់ស្លាប់ឆ្នាំណាទៅ?

គីមលាង ៖ ស្លាប់កាលសម័យបដិវត្តិ មិនបានស្លាប់ដោយគេវ៉ៃទេ គាត់ស្លាប់ដោយសារជំងឺគាត់ ។

ឈុនលី ៖ សម័យបដិវត្តិ អាកាលដើមមិនទាន់ចូលខ្មែរក្រហមហ្នឹង?

គីមលាង ៖ ហ្នឹងហើយ ។

ឈុនលី ៖ គាត់ធ្វើអីគេពីដើមមក?

គីមលាង ៖ មិនដែលធ្វើអីទេ គាត់ចាស់ហើយគាត់នៅតែមើលចៅឲ្យគេ គាត់ឈឺក៏ស្លាប់ដោយសារជំងឺខ្លួនឯង ។

ឈុនលី ៖ គាត់ឈ្មោះអីគេមីង?

គីមលាង ៖ ឈ្មោះ ពត ធិង ។

ឈុនលី ៖ ពត ធីម?

គីមលាង ៖ ធីង ។

ឈុនលី ៖ ពត ធីង?

គីមលាង ៖ ហ្នឹងហើយដែលគាត់ស្លាប់ ។

ឈុនលី ៖ ម្ដាយឈ្មោះអីមីង?

គីមលាង ៖ ឈ្មោះ នួន ស្រ៊ុប ។

ឈុនលី ៖ នួន សារ៉ីប?

គីមលាង ៖ នួន ស្រ៊ុប ។

ឈុនលី ៖ នួន...

គីមលាង ៖ នន់ នន់...

ឈុនលី ៖ នន់?

គីមលាង ៖ ហ្នឹងហើយ

ឈុនលី ៖ នន់ ស្រ៊ុប?

គីមលាង ៖ ហ្នឹងហើយ!ឪឈ្មោះពត ធីង ។ ហើយគាត់សម័យនោះគាត់អត់បាយផងបានកើតជាឈឺស្លាប់ជំងឺខ្លួនឯង ។

ឈុនលី ៖ អាហ្នឹងពេលមីងទៅធ្វើការតាមកងហើយនៅ?

គីមលាង ៖ តាមកងគេនោះឯង ចល័ត ។

ឈុនលី ៖ ចា៎!ចុះអាពេលមុនទៅធ្វើការនៅត្រពាំងថ្មហ្នឹងមានទៅធ្វើការនៅឯណាទៀតទេ?

គីមលាង ៖ អត់មានទៅធ្វើនៅឯណាទៀតទេមានតែត្រពាំងថ្មហ្នឹង ភ្នំកូនខ្វែង ។

ឈុនលី ៖ ចុះទៅធ្វើហ្នឹងខ្ទង់៧/៧?

គីមលាង ៖ ហ្នឹងឯង?

ឈុនលី ៖ ពេលហ្នឹងមីងទៅដំបូងអត់ទាន់មានអ្នកណាធ្វើទាំងអស់ហ្អី?

គីមលាង ៖ អត់ទេ ។

ឈុនលី ៖ នៅវាលនៅឡើយ?

គីមលាង ៖ នៅវាល អាទៅលើលកទំនប់ត្រពាំងថ្មនោះអត់ទាន់មានទេ មានតែកំលាំងពួកយុវជននារីនេះឯង មានតែដុបហើយលើកមិនរួចក៏គេមិនឲ្យឡើងហើយខ្លួនចេញចៃអស់ហើយសម័យនោះ ។

ឈុនលី ៖ អត់ឲ្យឡើងម៉ងហ្អី?

គីមលាង ៖ អត់ឲ្យឡើង ចេញចៃពីអាវទ្រនាប់តើនិយាយឲ្យត្រង់ទៅងើនេះងើសីលផង ។ ចៃញចៃមកដល់នេះទៀតដោះអាវទ្រនាប់ចេញមកឃើញចៃដូចចៃជ្រូកទៅហើយ ចៃពណ៌សហើយសំពត់គេបើកអាសំពុតរាងស ៗ ដូចកប្បាសចេះឯង ។

ឈុនលី ៖ ហើយចឹងធ្វើម៉េចទៅមីងបើមានចៃចឹង?

គីមលាង ៖ មានចៃក៏បេះញៀញៗហើយពាក់អាវទៅវិញទៅណាសកូនចេះតែស៊ូទាល់តែបានរស់ប៉ុណ្ណេះទៅណាស ។ កំសត់ណាស់ កាលនោះបើគេយកទៅវៃចោលម្ទេះផាប់បាត់មិនបានឃើញមុខម៉ែទេចេះតែស៊ូទ្រាំ សុំគេមកផ្ទះគេមិនឲ្យមក ។

ឈុនលី ៖ មីង បើយើងធ្វើអត់ហើយ គេអត់ឲ្យឡើងមកមិនអត់អីហូបហើយ?

គីមលាង ៖ បាយគេឲ្យឡើងមកហូបគេអត់បន្តត់ទេ តែយើងខ្លាចលើកមិនរួចចេះតែខ្លាចគេ ។

ឈុនលី ៖ ចឹងមិនសុខចិត្តអត់បាយខ្លួនឯង?

គឹមលាង ៖ សុខចិត្តឲ្យតែលើករួចទៅឡើងមកដេក បាយអត់ឃ្លានទេ សោខ្លាំងអត់ឃ្លានបាយទេ ។

ឈុនលី ៖ ស្អែកឡើងមានកំលាំងទៅទៀត?

គឹមលាង ៖ បេះតែទៅខ្លាចគេ បេះតែទៅ ។

ឈុនលី ៖ បីម៉ែត្រគឺបធំណាស់ណាមីង!

គឹមលាង ៖ បីម៉ែត្រគឺបអីបេះទទឹងកន្លះម៉ែត្រ ហួស!ទទឹងមួយម៉ែត្រ បណ្ដោយបីម៉ែត្រណាស ។

ឈុនលី ៖ ទទឹងមួយម៉ែត្រ ជំរៅកន្លះម៉ែត្រ បណ្ដោយបីម៉ែត្រ?

គឹមលាង ៖ ជំរៅកន្លះម៉ែត្រណាស នេះសម័យហ្នឹងឯង ។

ឈុនលី ៖ សំរាប់តែម្នាក់ទេ?

គឹមលាង ៖ សំរាប់ម្នាក់ ។

ឈុនលី ៖ ចឹងមួយក្រុមបណ្ដោយ៣០ម៉ែត្រ?

គឹមលាង ៖ ៣០ម៉ែត្រ ហើយអ្នកវែកទឹកម្នាក់ផង បើវែកមិនទាន់ចាប់ដាក់ម៉ែត្រគឺបឲ្យវែកទៀត ។

ឈុនលី ៖ ហើយវែកហ្នឹងកំប៉ុងតូចៗហ្នឹងទៅយកទឹក?

គឹមលាង ៖ អត់មាននេះទេ ចុះបំពង់ឬស្សីប្រវែងនេះបោះវាទៅបានៗដាក់ទឹកនៅនោះចែកគ្នា ។ ដងទឹកដាក់នៅក្នុងបំពង់បានយកមកចែកបងប្អូនហូបទាំងអស់គ្នា ហើយបំពង់ឬស្សីនោះ វែកម្នាង៥ឲ្យតែមានទឹកច្រើនបានផឹកច្រើន បើមិនមានច្រើនអត់បានអីផឹកទេ រកមិនបាន ច្រើនក៏តាមតិចទៅ ។

ឈុនលី ៖ អត់ដែលបានឆ្អែតទេទឹក?

គឹមលាង ៖ អត់ទេ!

ឈុនលី ៖ ចុះមិនឈឺហើយមីង?

គឹមលាង ៖ ឈឺ ឈឺឡើងសុំគេទៅសំរាកពេទ្យគេមិនឲ្យទៅគេថាឯងឈឺសតិអារម្មណ៍ ។ បើយើង ទៅធ្វើការគេអរ បើយើងមិនបានទៅគេថាយើងឈឺសតិអារម្មណ៍ ។ ដែលឈឺនោះដោយ សារអត់ទឹកមុជ ដោយសារចេញចៃមិនមានថ្នាំលេប មានតែថ្នាំអាចម៍ទន្សាយសម័យ នោះ សំបកឈើយើងដែលទៅលេបជាហួស!

ឈុនលី ៖ ចុះសំរាន្តទៅមិនរមាស់?

គឹមលាង ៖ រមាស់ យប់ឡើងទៅដោះអាវ ដោះអាវហើយហាលចេញសុទ្ធតែអំបិល ដោះអាវ ហាល ។

ឈុនលី ៖ ចឹងសំរាន្តដោះអាវ?

គឹមលាង ៖ ពាក់អាវផ្ទាស់ប្តូរ សុទ្ធតែស្រីគ្នាឯង ។

ឈុនលី ៖ អាវមានប៉ុន្មានទៅ?

គឹមលាង ៖ អាវមានតែពីរកំប្លេរប៉ុណ្ណោះឯង គេមិនដែលបើកឲ្យ ។

ឈុនលី ៖ ហើយអាវអត់ដែលបោកទេ?

គឹមលាង ៖ អត់ដែលបោកទេ ហាល ៗ ស្ងួតយើងពាក់ទៅវិញដល់ស្អែកឡើងពាក់អានោះទៅវិញបាន
ជាចេញចៃ ។

ឈុនលី ៖ ស្លៀកខោឬក៏ស្លៀកសំពត់មីង?

គឹមលាង ៖ ស្លៀកសំពត់ ។

ឈុនលី ៖ វែកដីស្លៀកសំពត់ទៀត?

គឹមលាង ៖ ស្លៀកសំពត់អត់មានខោបើកឲ្យទេ ។

ឈុនលី ៖ មានមួកពាក់ដែរអត់?

គឹមលាង ៖ មួកនោះមានមានមួកស្លឹកត្នោតមួយ ។

ឈុនលី ៖ ហើយមានក្រមាមួយ?

គឹមលាង ៖ ក្រមាមួយ ។

ឈុនលី ៖ ហើយអាហ្នឹងវែកឡើងទៅលើទៀតហ្អីមីង?

គឹមលាង ៖ វែកឡើងទៅលើខ្នងទំនប់ ។

ឈុនលី ៖ ហើយវែកឡើងទៅលើម៉េចទៀតទៅមីង?

គឹមលាង ៖ វែកឡើងទៅលើខ្នងទំនប់ណាស ខ្ពស់ណាស់ ។

ឈុនលី ៖ កំពស់ណាទៅ?

គឹមលាង ៖ ហ៊ឺស!ខ្ពស់ណាស់ទំបន់ស្ពានរាប ដល់មកពីស្ពានរាបរួចទៅអីត្រពាំងថ្ម ត្រពាំងថ្មរួចបាន
កូនខ្វែង ។ ចំណាំបានទេ?

ឈុនលី ៖ រាងវារាងយ៉ាងម៉េច?

គឹមលាង ៖ ចាំមើលណាស...មកពីពន្លៃស្វាយសរយើងនោះឯងអាស្វាយសចាស់នោះណាស កូនឯង
ធ្លាប់ស្គាល់ដែរហ្អាស?

ឈុនលី ៖ អត់ស្គាល់ផងមីង ។

គឹមលាង ៖ នោះឯងដែលលើកមុនដំបូងគេហៅទ្រនំមាន់ លើករួចបានទៅអានត្រពាំងថ្ម ចេញពីត្រពាំងថ្មទៅកូនខ្លែងចប់ត្រឹមកូនខ្លែងហើយបានទៅគរបីដើម គេឲ្យដើរមកយប់ទៀត ។ ត្រដាក់គេឲ្យដើរមកយប់បានជាពិបាកណាស់ ។

ឈុនលី ៖ មកយប់ចឹងមិនអត់បានដេក?

គឹមលាង ៖ អត់បានដេកទេ ដើរវាស់ព្រឹកដល់ពេលបានមុជទឹកមុជនៅយើងដើមគរ គរបីដើមនេះឯង ។

ឈុនលី ៖ ពីរខែកន្លះហ្អី?

គឹមលាង ៖ ពីរខែកន្លះ ។

ឈុនលី ៖ ចឹងបានន័យថាពីរខែកន្លះហ្នឹងមឹងដឹកហើយៗ?

គឹមលាង ៖ លើករួចហើយ លើករួចឡើងគេឲ្យមកគរបីដើម ចល័តនៅគបីដើម ។

ឈុនលី ៖ មកទាំងអស់គ្នាឬយ៉ាងម៉េច?

គឹមលាង ៖ មកទាំងអស់គ្នា មកគ្រប់ស្រុកគ្រប់ស្រែម៉ាស្រុកព្រះនេត្រព្រះទាំងអស់ ។

ឈុនលី ៖ ចុះអ្នកណាគេអ្នកមើលការខុសត្រូវវាស់វែងអីនោះ?

គឹមលាង ៖ អ្នកមើលការខុសត្រូវនោះប្រធានកងប៉ោយសំរោងឈ្មោះ បងបឿន តែគាត់ស្លាប់អស់ហើយ ។

ឈុនលី ៖ ហើយមានអ្នកណាទៀត?

គឹមលាង ៖ អត់ទេ ។

ឈុនលី ៖ ចុះពូសារឿន ពូល្អុតនោះ?

គឹមលាង ៖ អត់ដែលស្គាល់ទេ គេចល័តផ្សេង ។

ឈុនលី ៖ ហើយមនុស្សច្រើនទេមឹង?

គឹមលាង ៖ ច្រើន មនុស្សរាប់ពាន់រាប់លាននាក់ណាសទៅលើកទំនប់ ។

ឈុនលី ៖ ចឹងមិនមើលទៅខ្មៅអស់ហើយ?

គឹមលាង ៖ សុទ្ធតែខ្មៅដូតកន្សែងពាក់មួកស្លឹក ។

ឈុនលី ៖ ចុះមានអ្នកណាពេលធ្វើការចឹងសន្លប់ ដួលទេ?

គឹមលាង ៖ អត់ដែលមានទេ មានតែអ្នកពស់ចឹកឈ្មោះគេង ប្រជាជនថ្មី គាត់នៅដូនប្រែងតែគាត់ស្លាប់ហើយនៅសង្កាត់ស្រះដីក ។ គាត់ទៅរែកដីយប់ពស់ចឹក ប្រុស ។

ឈុនលី ៖ ពស់អីគេមឹង?

គឹមលាង ៖ ពស់ក្រឡាចាស់ ។

ឈុនលី ៖ ពស់ចំការចាស់?

គឹមលាង ៖ ក្រឡាចាស់ ចឹកពេលយប់ គ្រូខ្មែរមើលមិនទាន់ក៏ងាប់បណ្ដោយ ។

ឈុនលី ៖ ស្លាប់ភ្លាមៗ?

គឹមលាង ៖ ហ្នឹងហើយប្រកាច់ស្លាប់ភ្លាមៗ ឡើងចេញឈាមពីរោម ។

ឈុនលី ៖ ហើយមានអ្នកណាទៀតឈឺទេមីង?

គឹមលាង ៖ អត់ អត់មានអ្នកណាទៀតទេ ។

ឈុនលី ៖ ចុះមានអ្នកណាកំពុងតែធ្វើការគេហៅទៅណាទៅណីទេ?

គឹមលាង ៖ អត់ទេកូន មិនដែលបានជួបប្រទះរឿងចុះៗទេ ។

ឈុនលី ៖ មីងថាមេកងឈ្មោះ ជឿន?

គឹមលាង ៖ បឿន គាត់ស្លាប់ហើយ ។

ឈុនលី ៖ អ្នកស្រុកណា?

គឹមលាង ៖ អ្នកបាត់ដំបង គាត់មេកងអ្នកថ្មី ។

ឈុនលី ៖ ចុះមេកងធំជាងគាត់ទៀតនោះ?

គឹមលាង ៖ អត់ស្គាល់ទេមេកងមានតែគាត់ហ្នឹងឯង មេកងរងឈ្មោះ បងបឿនៗ ។ ប្រធានកងវរៈ មិនដឹងអ្នកណាទេស្គាល់តែគាត់មួយ ។

ឈុនលី ៖ ចុះស្គាល់ យាយចែម ទេមីង?

គឹមលាង ៖ ទេ យាយចែម ឮតែគេថា យាយចែមៗមិនដែលស្គាល់មុខទេ ។

ឈុនលី ៖ ចុះគេថា យាយចែម ហ្នឹងអ្នកណាគេ?

គឹមលាង ៖ មិនស្គាល់ទេ មិនដឹងថានៅឯណាទើបតែសម័យនេះហើយឮគេថា យាយចែមៗ ដែលយាក់ណាមចូលមកហើយគេថា យាយចែមៗ មិនដែលស្គាល់ទេ ។

ឈុនលី ៖ ចុះមីងមុនពេលធ្វើទំនប់ហ្នឹងអត់មានធ្វើការអីទៀតទេហ្អី?

គឹមលាង ៖ អត់ទេកូន មិនដែលបានធ្វើការអីទៀតទេ ។

ឈុនលី ៖ ចឹងវាឡើងដល់៧៧ហើយ ចុះអាខ្វង់៧៦នោះពេលដែលខ្មែរក្រហមចូលមកបានបួនប្រាំខែមីងធ្វើអី??

គឹមលាង ៖ ខ្មែរក្រហមឡើងមក មានធ្វើអីគេឲ្យធ្វើតែចល័ត ។

ឈុនលី ៖ ចល័តធ្វើអីគេ?

គឹមលាង ៖ ដក ស្ទួង នៅអារក្សបាក់កយើងជិតគោកលន់ ។ ស្គាល់ទេគោកលន់?

ឈុនលី ៖ អត់ស្គាល់ផង ។

គឹមលាង ៖ គោកលន់បៀតគោកពន្រ្ទ ក្បែរសាលាក្រៅនោះណាស ទៅតែចល័តប៉ុណ្ណោះឯងរួច ហើយទៅចល័តត្រពាំងថ្មអីចល័តត្រពាំងថ្មហើយកូនខ្វែងហើយគរបីដើមបានចប់ប៉ុណ្ណោះ ឯង ដល់គរបីដើមក៏យាក់ណាមចូលមក ។

ឈុនលី ៖ មីងគេថានៅកូនខ្វែងពិបាកដាំងហ្អី?

គឹមលាង ៖ កូនខ្វែងហ្នឹងហើយពិបាកដែលអត់ទឹកនោះ កាលនៅទំនប់ត្រពាំងថ្មក៏អត់ទឹកដែរ ។

ឈុនលី ៖ ប៉ុន្តែនៅកូនខ្វែងរឹតតែអត់ទៀត?

គឹមលាង ៖ អត់ អត់ដាំងអីទៅទៀត ដឹកវាមិនចេញ ។

ឈុនលី ៖ អត់មានទឹកហូបម៉ង?

គឹមលាង ៖ អត់ដឹកអណ្តូងក៏មិនចេញដែរ ពេលឡានគេដឹងទឹកទៅមួងៗដណ្តើមគ្នា ។

ឈុនលី ៖ គេដឹកឡានទៅ?

គឹមលាង ៖ គេដឹកឡានទៅឲ្យអ្នកដាំបាយ បើយើងទៅដណ្តើមគេថាឲ្យ ។ អ្នកណាដណ្តើមបានក៏បាន អ្នកណាអត់បានក៏អត់ទៅ ។

ឈុនលី ៖ ហើយដណ្តើមបានប៉ុណ្ណា?

គឹមលាង ៖ ឡានដឹកទឹកទៅម៉ាស៊ីនទែនឲ្យអ្នកដាំបាយ យើងទៅដណ្តើមទៅក្រែងបានយកមកដឹក ។

ឈុនលី ៖ ចុះមីងទៅដណ្តើមគេដែរ?

គឹមលាង ៖ ទៅដណ្តើមក៏គេមិនឲ្យយើងដង គេវែកមកដាក់តាមធុងខ្វាចអត់មានអីដាំបាយឲ្យយើងហូប កាលសម័យនោះ ដល់ទឹកយើងទៅរកហូបខ្លួនឯងអត់បានដឹកទេ ។

ឈុនលី ៖ គេដឹកមកពីណាវិញពូ?

គឹមលាង ៖ ឡានគេដឹកកាលបដិវត្តិគេដឹកយកមកដាំបាយ ។

ឈុនលី ៖ មិនដឹងដឹកមកពីខាងណា?

គឹមលាង ៖ មិនដឹងមកពីខាងណាទេឲ្យអ្នកដាំបាយ ។

ឈុនលី ៖ ហើយចឹងទៅកូនខ្វែងហ្នឹងយូរទៀតទេ?

គឹមលាង ៖ កូនខ្វែងប្រហែលមួយខែ មិនដល់មួយខែផងទៅកូនខ្វែង

ឈុនលី ៖ តូច?

គឹមលាង ៖ ទំនប់វាបត់ពីនេះរួចបត់ទៅលិចប៉ុណ្ណោះឯងរួចចប់បណ្តោយ ។

ឈុនលី ៖ មកពីកូនខ្វែង?

គឹមលាង ៖ គរបីដើម ។

ឈុនលី ៖ គរបីដើមនៅភូមិអីគេ?

គឹមលាង ៖ អត់មានភូមិទេ នៅខាងជើងព្រៃមាន់ គេរើផ្ទះអស់ហើយគរបីដើមហ្នឹងគេធ្វើផ្ទះឲ្យនៅផ្ទះក្បៀងវែងអីចេះម៉ាចល័តយុវជនផ្សេង នារីផ្សេងទៅមានបន្ទន់មានអីសំរាប់ឲ្យយើងបត់ជើងបត់ដៃ ។ មកនៅគបីដើមបានបាយម្នាក់ប៉ុណ្ណេះ តែគេឲ្យហូបមួយថ្ងៃបីដងដែលយើងមកស្ទូងស្រូវ ។

ឈុនលី ៖ ចុះកាលនៅទំនប់នោះបានបាយប៉ុន្មាន?

គឹមលាង ៖ នៅទំនប់នោះមួយថ្ងៃពីរដង ព្រឹកល្ងាច ។

ឈុនលី ៖ ធ្វើការធ្ងន់ហើយឲ្យពីរដង?

គឹមលាង ៖ ហ្នឹងហើយ ។

ឈុនលី ៖ បាយច្រើនទេ?

គឹមលាង ៖ បាយម៉ាកូនចានចង្កឹះប៉ុណ្ណេះ ។

ឈុនលី ៖ ជាមួយប្រហុក?

គឹមលាង ៖ ជាមួយប្រហុក គេស្ងោទឹកប្រហុក ។

ឈុនលី ៖ រាល់ថ្ងៃ?

គឹមលាង ៖ រាល់ថ្ងៃចេះឯងមិនដែលបានស្គាល់ជាតិត្រីទេ ចេះតែស៊ូទ្រាំទៅណាស ។

ឈុនលី ៖ ចេះតែមានកំលាំងដែរ អត់មានអ្នកស្លាប់ដោយសារបាក់កំលាំងទេ?

គឹមលាង ៖ កាលនៅតាមក្រុមអត់មានទេ ដែលនៅតាមក្រុមខ្ញុំអត់មានអ្នកណាទេ ខ្លាចតែនៅក្រុមផ្សេងគេមានសំលាប់មិនដឹងទេ បើក្រុមខ្ញុំអត់មានទេ ។

ឈុនលី ៖ ចុះដូចឈឺបាក់កំលាំងស្លាប់ ដូចរែកៗស្លាប់?

គឹមលាង ៖ ទេបើឈឺទៅដេកពេទ្យ ដូចគ្នារាំងរដូវអី ។ បើខ្ញុំរាំងតើ រាំងរដូវឡើងម៉ាឆ្នាំអត់ដែលមានអីទេទាល់តែមកផ្ទះបានរកគ្រូខ្មែរដឹកថ្នាំបានមាន ។

ឈុនលី ៖ គ្រប់គ្នាអីចឹងហ្អីមីង អត់ដែលមានអាហ្នឹង?

គឹមលាង ៖ អត់ គ្រប់គ្នាយើងស៊ីខ្វះខាត ទឹកក៏មិនមានផ្អូតទេខ្វះខាតទាំងអស់ ស្គមដែលជីវភាពកាលសម័យនោះយ៉ាប់ណាស់រកអីវាមិនគ្រប់គ្រាន់ទេបើស៊ីគ្រប់គ្រាន់មិនដែលមាននារីខះរដូវទេ ។

ឈុនលី ៖ ចឹងមីងរាំងតែមួយឆ្នាំទេ?

គឹមលាង ៖ តែមួយឆ្នាំ ហួសរាំងសម័យនោះដល់ពេលយាក់ណាមចូលបានខ្ញុំមកផ្ទះ ម៉ែគាត់រកគ្រូខ្មែរ ស្វោថ្នាំខ្មែរផឹក ។

ឈុនលី ៖ ចឹងម៉ារបបហ្នឹងអត់មានម៉េង?

គឹមលាង ៖ អត់ អត់រហូត ។

ឈុនលី ៖ ស្រីៗអីចឹងទាំងអស់ហ្អី?

គឹមលាង ៖ អត់រហូតឡើងយើងកើតជាភេទប្រុសវិញហើយអត់រហូត ចុះរែកតែធូន់នោះកូន កំសត់ណាស់កូនអឺយសម័យនោះ ។

ឈុនលី ៖ មីងដល់ពេលដុតពីគរបីដើមមកនៅទីណាទៀត?

គឹមលាង ៖ យាក់ណាមចូលមកក៏មកផ្ទះបណ្តោយ ។

ឈុនលី ៖ ហើយមកដល់ក្នុងផ្ទះហ្នឹងមកដល់ក្នុងភូមិម៉េចទៅ?

គឹមលាង ៖ មកដល់ក្នុងភូមិរកម៉ែក៏រកមិនឃើញ ផ្ទះក៏គេរើចេញអស់គាត់គេឲ្យទៅនៅអីវាលស្រែឯណោះដល់ខ្មែរក្រហមរត់អស់បាចចូលមកនៅភូមិបានមកធ្វើផ្ទះធ្វើសំបែងនៅ ។

ឈុនលី ៖ ចុះទៅរកគាត់នៅឯណាឃើញទៅ?

គឹមលាង ៖ ទៅឃើញនៅអីត្រពាំងតាចាប ។

ឈុនលី ៖ ចេះតែដើររកទៅ?

គឹមលាង ៖ ចេះតែដើររក ។

ឈុនលី ៖ ហើយមានគេមកជាមួយមីងច្រើនដែរ?

គឹមលាង ៖ មក ចេះតែដើរសួរគេទៅ សួររកគាត់ គាត់ទៅនៅអីត្រពាំងតាចាបអីនោះពីនាក់បងខ្ញុំដែលមេម៉ាយនោះ ។ គាត់ក៏មេម៉ាយដែរកាលបដិវត្តិឪស្លាប់នោះ ។

ឈុនលី ៖ ចុះមីងមានបងប្អូនប៉ុន្មាននាក់?

គឹមលាង ៖ បងប្អូនមានប្អូននាក់ឈ្មោះ គានិលមួយ អ៊ីនួនមួយ នីមួយ អីណោះមួយ ហួស!បងប្អូនប្រាំនាក់ស្រីពីរ ប្រុសបី ។

ឈុនលី ៖ ចុះមីងកូនទីប៉ុន្មាន?

គឹមលាង ៖ ខ្ញុំពៅគេ ។

ឈុនលី ៖ ហើយបងប្អូនមីងអត់មានបាត់បង់ទេហ្អី?

គឹមលាង ៖ បាត់បង់ បងប្អូនប្រាំមួយនាក់ បាត់បង់ម្នាក់បាត់បង់កាលសម័យនោះ ប៉ុល ពត គេយកទៅសំលាប់ ។

ឈុនលី ៖ មិនមែនបងប្អូនបង្កើតទេ?

គឹមលាង ៖ បងបង្កើត បងប្អូនប្រាំមួយនាក់ បងធំគាត់ធ្វើទាហានគេយកទៅវៃចោល ។

ឈុនលី ៖ ទាហានជំនាន់ណា?

គឹមលាង ៖ ទាហានជំនាន់ លន់ នល់ ។

ឈុនលី ៖ មីងមានកូនប៉ុន្មាននាក់?

គឹមលាង ៖ កូនបួននាក់ ។

ឈុនលី ៖ បានរៀនទេ?

គឹមលាង ៖ កូនរៀនតែអាពៅគេថ្នាក់ទី៧ ។

ឈុនលី ៖ ចុះកូនបងៗ?

គឹមលាង ៖ កូនបងៗអត់បានរៀនទេ រៀនត្រឹមថ្នាក់ទី៧ឈប់អស់ហើយ

ឈុនលី ៖ ទៅណាវិញ?

គឹមលាង ៖ នៅនេះទាំងអស់គ្នា អត់ធ្វើអីទេធ្វើស្រែទាំងអស់គ្នា ។

ឈុនលី ៖ កូនសុទ្ធតែប្រុស?

គឹមលាង ៖ ស្រីម្នាក់ ។

ឈុនលី ៖ ស្រីអាពៅគេហ្នឹង?

គឹមលាង ៖ ទេក្រមុំហើយដើរទៅណាហើយ ។

ឈុនលី ៖ ចឹងមីងមានផ្ទះពីរ?

គឹមលាង ៖ នេះផ្ទះ!

ឈុនលី ៖ ចុះនោះ?

គឹមលាង ៖ ផ្ទះបង ។

ឈុនលី ៖ អត់មានកូនចៅទៅថៃនឹងគេទេហ្អី?

គឹមលាង ៖ អត់ទេ ។

ឈុនលី ៖ មីងធ្វើស្រែបានច្រើនទេ?

គឹមលាង ៖ ស្រែមានតែរបបដែលគេចែក ។

ឈុនលី ៖ បានច្រើនទេមីង?

គឹមលាង ៖ ទេ បានម៉ារ៉ៃ ម្នាក់ម៉ារ៉ៃកូនបួននាក់បួនរ៉ៃមិនមានអីទេកូន ។

ឈុនលី ៖ ហើយចឹងមានអាត្រាក់ភ្ជួរខ្លួនឯង?

គឹមលាង ៖ ភ្ជួរ មានគោយន្តភ្ជួរ ។

ឈុនលី ៖ ចុះមានធ្វើអីទៀតទេមីង?

គឹមលាង ៖ អត់មានធ្វើអីទេចេះតែធ្វើនឹងគេដាំឪឡឹក ត្រសក់ ឲ្យទៅរកស៊ីឆ្ងាយនឹងគេអត់បានទៅទេ ។

ឈុនលី ៖ ចុះឆ្នាំនេះបានឪឡឹកលក់ដែរ?

គឹមលាង ៖ ឆ្នាំនេះមិនបានដាំទេ កូនរវល់តែធ្វើផ្ទះឲ្យគេស៊ីឈ្នួលគេ កូនជាង ។

ឈុនលី ៖ អ្នកណាគេធ្វើជាង?

គឹមលាង ៖ បងគេ អត់ទាន់មានគ្រួសារមានអីនឹងគេទេអាយុឡើងសាមជាងហើយ ។

ឈុនលី ៖ ចុះគ្រួសារមីង?

គឹមលាង ៖ គាត់ស្លាប់ហើយ ។

ឈុនលី ៖ ស្លាប់ពីអង្កាល់?

គឹមលាង ៖ ស្លាប់ប្រហែល១០ឆ្នាំហើយ គាត់ឈឺ ឈឺតែក្បាលតែបីថ្ងៃឈប់និយាយឈប់អីរហូត ។

ឈុនលី ៖ ប្រហែលជាទាក់ទងរឿងលើសឈាមផងទេដឹង ។

គឹមលាង ៖ កាលដែលគាត់ស្លាប់នឹងកូននៅតូចៗ ។

ឈុនលី ៖ ប្រាំឆ្នាំហើយ?

គឹមលាង ៖ ប្រាំអីឡើងប្រាំបុិលឆ្នាំហើយតាំងពីថ្ងៃ៧កើតខែផល្គុន ៧ឆ្នាំហើយ យូរហើយ ។

ឈុនលី ៖ តាំងពីរ២០០៨?

គឹមលាង ៖ ហ្នឹងហើយ កូនអាបងធំជាងគេ អាប្អូនៗតូចៗបួសមុខភ្លើង ។ មិនដែលបានទៅថៃអីនឹងគេទេកូនអើយធ្វើស្រែនៅតែធ្វើផ្ទះឲ្យគេស៊ីឈ្នួលគេមួយថ្ងៃមួយរយហាសិបរៀលប្រាក់ខ្មែរ...

ឈុនលី ៖ លុយខ្មែរមួយម៉ឺនប្រាំហ្អី?

គឹមលាង ៖ មួយម៉ឺនប្រាំ អាប្អូនក៏មិនបានធ្វើអាមួយនោះរៀននៅទាំងអស់គ្នាហ្នឹង យ៉ាប់ ។ មិនដឹងរកអីទេកូនអើយ កូនសុទ្ធតែល្ងង់ ។

ឈុនលី ៖ មីងថាបងមីងធ្វើទាហានហ្នឹងគេយកទៅសំលាប់ហ្អី?

គឹមលាង ៖ តែគាត់ធ្វើទាហានទៅឯស្រុកព្រៃតូចអីណោះ ព្រៃតូចបៀតស្រុកមោងដល់បានប្រពន្ធទៅនៅឯនោះ គេសំលាប់ចោល ។

ឈុនលី ៖ ឆ្នាំណាទៅ?

គឹមលាង ៖ មិនចំណាំឆ្នាំបានទេដែលគេយកទៅសំលាប់ ។ ពេលយាក់ណាមចូលហើយណាស គេយកទៅសំលាប់ កំពុងតែវ៉ៃវ៉ិ គេយកទៅសំលាប់ចោល ។ តែគាត់បានគ្រួសារហើយ គាត់បែកផ្សេងគាត់ទៅនៅតាមប្រពន្ធគាត់ ។ តាមប្រពន្ធគាត់នៅអីស្រុកព្រៃតូចជិតមោងអីបៀតបាត់ដំបង ។

ឈុនលី ៖ ពុគេថាហ្អី?

គឹមលាង ៖ ហ្អឹងហើយពុតែគេថា តែប្រពន្ធកូនមិនដែលឃើញមុខទេអត់ដែលឃើញកមកលេងទេ ។

ឈុនលី ៖ បាត់រហូតហ្អី?

គឹមលាង ៖ បាត់រហូត ។

ឈុនលី ៖ ចុះមីងដែលទៅកន្លែងអាងត្រពាំងថ្មទៀតដែរទេ?

គឹមលាង ៖ អត់ទេ ចាស់ប៉ុណ្ណេះហើយមិនដែលបានទៅឃើញអាងនោះទេ បើឃើញៗកាលលើកដល់ក្រោយពីនោះមិនដែលបានឃើញ មិនដែលបានទៅមើលទេ ។

ឈុនលី ៖ មីងឃើៗរបៀបម៉េចអាកាលទៅធ្វើអាងនោះ?

គឹមលាង ៖ ឃើឡើងស្គមរាំងខែងើកដៃឡើងប៉ុនកវែកហើយចេះតែស៊ូទ្រាំងឡើងមកដល់ថ្ងៃនេះហើយ ។

ឈុនលី ៖ ឃើតែរបៀបចឹងទេអត់ដែលចាញ់គ្រូនញាក់អីទេ?

គឹមលាង ៖ អត់ ។

ឈុនលី ៖ នៅនោះព្រៃហ្អី?

គឹមលាង ៖ ព្រៃសុទ្ធតែលើកដីកាប់ព្រៃកាប់អីអស់ហើយបានយើងតំរង់ ។ គេដាក់បបញ្ឈូឈើអីហើយបានគេវាស់ម៉ែត្រគីប ហើយគេប្រើឲ្យទៅកាប់ឬស្សីនៅក្នុងព្រៃទៀត ។

ឈុនលី ៖ កាប់ឬស្សីធ្វើអីគេ?

គឹមលាង ៖ ដឹងតែកាប់ កាលនោះគេកាប់យកមកធ្វើខ្ទមទៅកាប់អីព្រៃ ឃើញដំរីនាំគ្នារត់ឡើងខ្លាច ។

ឈុនលី ៖ ឃើញអីគេមីង?

គឹមលាង ៖ ដំរី ។

ឈុនលី ៖ ហ្អស!ដំរី ។

គឹមលាង ៖ ខ្លាចដំរីដេញនាំគ្នារត់ ចេះតែទៅតាមគេទៅ ។

ឈុនលី ៖ ចឹងដំរីអត់ដេញដែរ?

គឹមលាង ៖ ទេ អត់អីទេដឹរនោះ ។

ឈុនលី ៖ កុំឲ្យតែយើងធ្វើអីវា?

គឹមលាង ៖ ហ្នឹងហើយ ។

ឈុនលី ៖ ចុះមីងដែលព្រួគេថាសំលាប់មនុស្សទេ?

គឹមលាង ៖ ទេ មិនដែលបានឃើញទេ ។

ឈុនលី ៖ ចុះអាកាលគេវៃអ្នកដែលខុសសីលធម៌នោះ?

គឹមលាង ៖ មិនដែលបានឃើញទេ មិនដែលបានជួបប្រទះទេ ។

ឈុនលី ៖ អត់ដែលបានលើកដីនៅទំនប់រន្ទះបាញ់ទេ?

គឹមលាង ៖ អត់ទេ រន្ទះបាញ់អត់ដែលទេ ឡើងពីច្រូតស្រូវគេឲ្យទៅចល័តតែម្តង គេស្មុកអត់ឲ្យចូលភូមិ ទៅចល័តតែម្តងមិនឲ្យមកជួបម៉ែឪផង ។

ឈុនលី ៖ មីងក្រោយមកមីងខស្សានិយាយរឿងរ៉ាវប្រាប់កូនចៅទៀតទេ?

គឹមលាង ៖ និយាយប្រាប់កូនៗវាមិនជឿទេ និយាយប្រាប់អាបងវាមិនជឿ ។ និយាយប្រាប់កូនៗ ថាបើសប្បាយដូចកូនឯងមិនបានរស់ទេ បើមិនបានធ្វើការគេផ្តាច់របបយើងមិនបានអីស៊ី ទេ ទាល់តែយើងធ្វើការបានមានរបបឲ្យយើង វាមិនជឿ ។

ឈុនលី ៖ អត់ជឿចឹងមីងខឹងដែរ?

គឹមលាង ៖ ទេ អត់ខឹងនឹងកូនទេ ចេះតែនិយាយប្រាប់កូនរហូត អត់ដែលខឹងនឹងកូនទេ ។

ឈុនលី ៖ មីងនៅនឹកឃើញទេរបបហ្នឹង?

គឹមលាង ៖ នៅតែនឹកឃើញ នឹកឃើញថាគេបន្តត់បាយបន្តត់អីចេះតែនឹកឃើញ ។

ឈុនលី ៖ មីងដែលដឹងរឿងតុលាការកាត់ទោសខ្មែរក្រហមទេ?

គឹមលាង ៖ មិនដែលដឹង មិនដែលបាននេះទេ ។

ឈុនលី ៖ អត់ដែលស្តាប់វ៉ាត់យូទេ?

គឹមលាង ៖ មិនដែលមានវ៉ាត់យូផង ទូរស័ព្ទនិយាយទៅក៏មិនដែលមាន ។

ឈុនលី ៖ ទូរស័ព្ទអត់មានទេ?

គឹមលាង ៖ អត់ ទូរទស្សន៍ក៏មិនមាន បើមានក៏មិនចេះបើក ។

ឈុនលី ៖ ចុះកូនៗមើលទូរទស្សន៍ឯណា?

គឹមលាង ៖ មើលនៅផ្ទះបង គាត់មានចេះតែមើលទៅដាក់តែស៊ីឌីមើល ។

ឈុនលី ៖ មើលរឿងថៃទេដឹង?

គីមលាង ៖ មើលតែអាក្រឹមគេកំប្លែង ។

ឈុនលី ៖ ឥឡូវមានតុលាការកាត់ទោស កាត់ទោស នួន ជា អៀង សារី អីធ្លាប់ឮឈ្មោះទេមីង? នួន ជា អៀង សារី អៀង ធីរិទ្ធ ខៀវ សំផន តាម៉ុកអីមេខ្មែរក្រហម មីងធ្លាប់ឮឈ្មោះទេ?

គីមលាង ៖ មិនដែលមានវ៉ាត់យូស្តាប់...

ឈុនលី ៖ ចុះកាលពីដើមដែលឮអត់?

គីមលាង ៖ មិនដែលឮទេកូនអើយ!មិនដែលមានវ៉ាត់យូ បើមានចេះតែស្តាប់នឹងគេ ។

ឈុនលី ៖ មីងចង់ឲ្យគេកាត់ទោសពួកខ្មែរក្រហមអស់ហ្នឹងដែរ?

គីមលាង ៖ ចង់ឲ្យគេកាត់ទោសណាស!

ឈុនលី ៖ តែពួកគាត់ចាស់ៗអស់ហើយ ចឹងចង់ឲ្យកាត់ដែរ ។

គីមលាង ៖ ចង់ឲ្យកាត់តើដែលកាលនោះធ្វើបាបយើងយ៉ាងណាឲ្យកាត់ទោសទៅ ។

ឈុនលី ៖ មានអីចង់បន្ថែមទៀតទេមីង?

គីមលាង ៖ អត់មានអីទេ ។

ឈុនលី ៖ ចឹងអគុណហើយមីងណាស ចឹងខ្ញុំសុំថតរូបមីង!

គីមលាង ៖ ចា៎!

«ចប់»